## សេចក្តីប្រកាសពត៌មាន

ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០
ទំនាក់ទំនង: មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ, 562.570.NEWS,
jic@longbeach.gov

សំរាប់ផ្សព្វផ្សាយបន្ទាន់

# សាលាក្រុងឡុងប៊ីឆអភិវឌ្ឍន៍នូវប្រព័ន្ធ ដើម្បីភ្ជាប់អ្នកផ្តល់នូវឧបករណ៍ការពារផ្ទាល់ខ្លួន និងវេទិការផ្លាស់ប្តូរប្រដាប់ប្រដាគ្របមុខ តាមអនឡាញ

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា - សាលាក្រុងឡុងប៊ីឆបានអភិវឌ្ឍន៍នូវប្រព័ន្ធដើម្បីភ្ជាប់អ្នកផ្តល់ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE), ក៏ដូចជាមធ្យោបាយមួយ សំរាប់អោយប្រជាជនធ្វើការបរិច្ចាគនូវទំនិញ និងសេវាកម្មនានា និងការទទួលបាននូវប្រដាប់ប្រដាគ្របមុខ តាមរយៈវេទិការផ្លាស់ប្តូរអនឡាញ។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "មានមនុស្សជាច្រើនបានបង្កើន និងបានត្រៀមខ្លួនជាស្រេចដើម្បីជួយ,"។ "ប្រព័ន្ធថ្មីរបស់យើង ភ្ជាប់អ្នកទាំងឡាយណាដែលត្រូវការ PPE ជាមួយនិងអ្នកទាំងឡាយណា ដែលអាចផ្តល់អោយ ឬបង្កើតនូវការផ្គត់ផ្គង់ចាំបាច់នានា"។

### ការស្នើសុំ PPE វេជ្ជសាស្ត្រ:

អង្គការដែលមានគុណសម្បត្តិទាំងឡាយ ដែលមានតំរូវការនូវ PPE, រួមមានទាំងកន្លែងថែទាំសុខភាព អ្នកផ្តល់សេវាវេជ្ជសាស្ត្រ ទីជំរក កន្លែងថែទាំមនុស្សពេញវ័យពេលថ្ងៃ និងកន្លែងថែទាំរយៈពេលយូរ អាចធ្វើសេចក្តីស្នើសុំ នូវគ្រឿងផ្គត់ផ្គង់តាមរយៈវេបសាយ longbeach.gov/COVID19 របស់ស៊ីធី, នៅក្រោម "ធនធាននានា សំរាប់អ្នកថែទាំសុខភាព" ឬ "Resources for Healthcare Providers."។

### ការបរិច្ចាគសំភារៈទៅកាន់ស៊ីធី:

ដើម្បីធ្វើអោយប្រសើរឡើង និងគ្រប់គ្រងនូវការបរិច្ចាគ ឬអំណោយ និងការផ្តល់ជំនួយទៅកាន់សាលាក្រុងឡុងប៊ីឆ ស៊ីធីផងដែរបានអភិវឌ្ឍន៍នូវ ទំរង់ អនឡាញមួយ ដែលអាចនិងត្រូវបំពេញដោយអាជីវកម្ម តាមមូលដ្ឋាន និងអ្នកស្ម័គ្រចិត្តសហគមន៍ទាំងឡាយ ដែលមានចំណាប់អារម្មណ៍ក្នុងការផ្តល់ជំនួយ។

ទំរង់ថ្មី នឹងជួយអោយស៊ីធីរៀបចំអំណោយ ដែលបានផ្តល់អោយ ដូចជាការប្រើប្រាស់កន្លែងអាជីវកម្ម ការដឹកជញ្ជូន និងសេវាកម្មបញ្ជូន និងសំភារៈការពារផ្ទាល់ខ្លួន។ លើសពីនេះទៀត អំណោយជាអាហារ និងគ្រឿងសំភារៈអនាម័យផ្ទាល់ខ្លួន សំរាប់អ្នកដែលកំពុងប្រឈមភាពគ្មានផ្ទះសំបែង និងការផ្តល់នូវសេវាស្ម័គ្រចិត្តតាមជំនាញផ្សេងៗជាច្រើន បានដាក់ចូលនៅក្នុងទំរង់។ ពត៌មានទាំងអស់ដែលផ្តល់អោយ បានត្រូវការពារដោយអេឡិចត្រូនិចនូវភាពឯកជន និងត្រូវបានពិនិត្យដើម្បីផ្គូរផ្គងគ្នាដ៏ប្រសើរ ជាមួយតំរូវការប្រតិបត្តិការរបស់ស៊ីធី។

**ការបង្កើតការផ្លាស់ប្តូរប្រដាប់ប្រដាគ្របមុខផ្សេងៗ តាមអនឡាញ:**

របាំងមុខ ឬម៉ាស់ និងប្រដាប់គ្របមុខសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ អាចនិងរកទិញបានតាមរយៈផ្សារ ដែលបានបង្កើតឡើងដោយ*ប៉ុស្តិ៍ឡុងប៊ីច (Long Beach Post)* ក្នុងភាពជាដៃគូរជាមួយសាលាក្រុងឡុងប៊ីច។ អ្នកផលិតរបាំងមុខ និងអាជីវកម្មទាំងឡាយ អាចចុះឈ្មោះបានតាមរយៈទំរង់ចុះឈ្មោះរបស់អ្នកលក់ ឬ Vendor Registration form។ *ប៉ុស្តិ៍ឡុងប៊ីច* និងសាលាក្រុង មិនទទួលបានប្រាក់កំរៃជើងសារ ពីការលក់ផលិតផលនានា តាមរយៈផ្សារឡើយ។ របាំងមុខ N95 និងរបាំងមុខប្រភេទវះកាត់នានា មិនគួរប្រើប្រាស់ដោយអ្នកលក់ដែលចូលរួមក្នុងកម្មវិធីនេះឡើយ ក្នុងខណៈដែលម៉ាស់ទាំងអស់នោះ គួរលៃទុកបំរុងសំរាប់បុគ្គលិកពេទ្យទាំងឡាយវិញ។

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីចកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

###